# គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង

**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ**

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍* *ថ្ងៃសុក្រ ទី២៣ ខែមករា ឆ្នាំ២០០៩* *ព្រឹត្តិប័ត្រលេខ៦៩ ឆ្នាំទី២*


| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -នៅឆ្នាំ២០០៨នេះករណីចាប់ខ្លួនប្រជាពលរដ្ឋដាក់ពន្ធនាគារកើនឡើង | ១ |
| -ប្រជាពលរដ្ឋនៅខេត្តសៀមរាបលើកគ្នាមកតវ៉ានៅមុខតុលាការខេត្ត | ២ |
| - ប្រធានគណបក្សសិទ្ធិមនុស្សចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅខេត្តកំពង់ឆ្នាំង | ៣ |
| - ចលនាប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរនៅកម្ពុជា | ៣ |


## នៅឆ្នាំ២០០៨នេះករណីចាប់ខ្លួនប្រជាពលរដ្ឋដាក់ពន្ធនាគារកើនឡើង

អង្គការសង្គមស៊ីវិល បានឱ្យដឹងថានៅឆ្នាំ២០០៨នេះករណីចោទប្រកាន់ និងចាប់ខ្លួនប្រជាពលរដ្ឋដាក់ពន្ធនាគារក្នុងរឿងវិវាទដីធ្លីមានការកើនឡើងបើធៀបទៅនឹងឆ្នាំ២០០៧ កន្លងទៅ ។

លោក **អាំ សំអាត** មន្ត្រីស៊ើបអង្កេតនៃអង្គការលីកាដូដែលមានមូលដ្ឋាននៅក្រុងភ្នំពេញបានគូសបញ្ជាក់ថា នៅឆ្នាំ២០០៨នេះមានប្រជាពលរដ្ឋ៤២នាក់ ដែលត្រូវបានតុលាការចាប់ខ្លួនពាក់ព័ន្ធទៅនឹងករណីដីធ្លីដូចជានៅខេត្តសៀមរាប ខេត្តស្វាយរៀង ខេត្តបាត់ដំបង ខេត្តរតនគីរី ក្រុងព្រះសីហនុ និយាយរួមទៅគឺស្ទើរតែគ្រប់ខេត្ត-ក្រុង ។ ការចាប់ខ្លួនប្រជាពលរដ្ឋក្រោមបទចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ពីបទបង្ករបួសស្នាម និងបំណងចូលកាន់កាប់សិទ្ធិអ្នកដទៃដោយខុសច្បាប់ ។

លោកបន្តថា ដីខ្លះមិនទាន់មានប្លង់កម្មសិទ្ធិផងតែគេបានចោទប្រកាន់ពីបទចូលកាន់កាប់កម្មសិទ្ធិអ្នកដទៃ ដោយខុសច្បាប់នេះជារឿងអយុត្តិធម៌សំរាប់ប្រជាពលរដ្ឋខ្មែរ ។ នៅឆ្នាំ២០០៨នេះតុលាការដែលបានចាប់ខ្លួន និងបានដោះលែងប្រជាពលរដ្ឋមានចំនួនប្រមាណ៧០នាក់ប៉ុណ្ណោះ ។ លោក **អាំ សំអាត** បានបន្ថែមថាតាមទស្សនាទានរបស់អង្គការលីកាដូមើលឃើញថា ប្រព័ន្ធតុលាការនៅប្រទេសកម្ពុជាត្រូវតែពង្រឹង និងកែប្រែដើម្បីឱ្យតុលាការក្លាយទៅជាតុលាការឯករាជ្យ និងផ្តល់ទំនុកចិត្តដល់ប្រជាពលរដ្ឋ ។

លោក **ធន សារ៉ាយ** ប្រធានសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៏នៅកម្ពុជា បានមានប្រសាសន៏កាលពីគ្រាកន្លងទៅថា នៅឆ្នាំ២០០៧ មានប្រជាពលរដ្ឋ១៣៩នាក់ ត្រូវបានចោទប្រកាន់ និងចាប់ខ្លួន ប៉ុន្តែនៅឆ្នាំ២០០៨មាន១៤៦នាក់ត្រូវបានចោទ និងចាប់ខ្លួន ហើយយ៉ាងហោចណាស់ក៏មានប្រជាពលរដ្ឋ៥៥នាក់ផងដែរស្ថិតក្នុងពន្ធនាគារ ។ ក្នុងនោះក៏មានការចាប់ខ្លួនហើយដោះលែងទៅវិញ ដើម្បីជាការបំបាក់ស្មារតីក្នុងការតវ៉ារឿងដីធ្លី ។

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្ស មានប្រសាសន៏ថា អ្នកមានលុយមួយចំនួនមានខ្នងបង្អែក និងពួកអ្នកមានអំណាច ដូច្នេះហើយប្រជាពលរដ្ឋដែលលោកទាមទារការពារផលប្រយោជន៏ គឺត្រូវបានតុលាការចាប់ឃុំឃាំងដើម្បីជាការគំរាមដល់អ្នកដែលបន្ត និងមានគំរោង

ធ្វើសកកម្មភាពនោះ ។ ដោយទៀតច្បាប់នៅប្រទេសកម្ពុជាស្ថិតនៅលើអ្នកមានអំណាច ឯអ្នកទន់ខ្សោយអត់មានច្បាប់ ។ លោកបានកត់សំគាល់ថាប្រព័ន្ធតុលាការមិនឯករាជ្យ បានធ្វើបាបប្រជាពលរដ្ឋសព្វបែបយ៉ាង ហើយតុលាការសំរាប់តែជួយអ្នកមានអំណាចមានលុយ និងឧកញ៉ាតែប៉ុណ្ណោះ ។ រីឯមន្ត្រីសំរបសំរួលនៃសមាគមអាដហុក ដែលមានទីតាំងនៅខេត្តរតនគីរីបានបញ្ជាក់ថា ប្រព័ន្ធយុត្តិធមិនៅខេត្តរតនគីរី ទាក់ទិននឹងការដោះស្រាយបញ្ហាដល់ជនជាតិភាគតិច ជាពិសេសការពារព្រៃឈើពីព្រោះបុគ្គលដែលរំលោភកាប់រំលំព្រៃឈើប្រណិតធ្វើអាជីវកម្មយ៉ាងអានាធិបតេយ្យសុទ្ធតែមន្ត្រីធំ និងក្រុមហ៊ុនឯកជន ។ យើងឃើញថា ប្រព័ន្ធយុត្តិធមិមិនបានបំរើឱ្យសហគមន៍ជនជាតិភាគតិចទេ ហើយទីបំផុតជនជាតិភាគតិចជាអ្នករងគ្រោះទៅវិញ តួយ៉ាងមានការចាប់ខ្លួន ឃុំឃាំងតំណាងសហគមន៍ជនជាតិទំពួនម្នាក់ និងម្នាក់ទៀតកំពុងរត់គេចខ្លួន ។ លោកបានបញ្ជាក់បន្ថែមថា ពលរដ្ឋប្តឹងប្តល់ពីបទល្មើសព្រៃឈើទីបំផុត ត្រូវបានគេចាត់ទុកថាពួកគាត់ប្រឆាំងទៅនឹងការអភិវឌ្ឍន៍ហើយអ្នករងគ្រោះគឺជនជាតិដើមភាគតិច និងសង្គមស៊ីវិល ដែលគេចោទប្រកាន់ថា ជាអ្នកញុះញង់ទៅវិញ ។

## ប្រជាពលរដ្ឋនៅខេត្តសៀមរាបលើកគ្នាមកតវ៉ានៅមុខតុលាការខេត្ត

ប្រជាពលរដ្ឋនៅឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ជាង២០០គ្រួសារ បានតវ៉ាទាមទារនៅសាលាឃុំ ស្រែណូយដើម្បីឱ្យអាជ្ញាធរឃុំចេញមុខមកដោះស្រាយបញ្ហាដីធ្លី ដែលក្រុមហ៊ុន **ម៉ានយ៉ាគ្រុប** កំពុងឈូសឆាយ ហើយអាជ្ញាធរឃុំស្រែណូយ ក៏រងការចោទប្រកាន់ថា លួចដីប្រជាពលរដ្ឋ ប្រមាណ៧០០០ហិកតាលក់ទៅឱ្យក្រុមហ៊ុន ។

អ្នកភូមិស្រែណូយ ឃុំស្រែណូយ បានរៀបរាប់ថាដីផ្ទាល់ខ្លួនរបស់គាត់ចំនួន៧ហិកតា ដែលបានកាន់កាប់តាំងពីឆ្នាំ១៩៧៩មកម្ល៉េះ ប៉ុន្តែឥឡូវនេះដីរបស់គាត់ក៏ដូចជាអ្នកភូមិផ្សេងទៀតត្រូវបានលោកមេឃុំលួចលក់ទៅឱ្យក្រុមហ៊ុន ដោយមេឃុំយកលេសថាប្រជាពលរដ្ឋបានលក់ដីនោះទៅឱ្យក្រុមហ៊ុន ។ គួរបញ្ជាក់ថាក្រុមហ៊ុន **ម៉ានយ៉ាគ្រុប** បានឈូសឆាយដីធ្លីរបស់អ្នកភូមិ ហើយប្រជាពលរដ្ឋផ្អើលឆោឡោ ក៏នាំគ្នាតវ៉ាដើម្បីឱ្យក្រុមហ៊ុនបញ្ឈប់ការឈូសឆាយដីធ្លីរបស់ពួកគាត់ ដោយក្រុមហ៊ុន **ម៉ានយ៉ាគ្រុប** បានឈូសឆាយដីធ្លី ធ្វើស្រែចំការរបស់អ្នកភូមិទាំងយប់។ បុរសរូបនោះបន្តថា ប្រជាពលរដ្ឋមិនបានលក់ដីនោះឱ្យក្រុមហ៊ុនទេ តាមពិតអាជ្ញាធរឃុំ លួចដីអ្នកភូមិលក់ទៅឱ្យក្រុមហ៊ុន ហើយពួកគាត់មកតវ៉ានៅសាលាឃុំស្រែណូយ ដើម្បីឱ្យអាជ្ញាធរឃុំរក្សាទុកដីរបស់អ្នកភូមិឱ្យនៅដដែល ។

លោក **ប៉ែន រតនា** អគ្គលេខាធិការរណសិរ្សប្រជាធិបតេយ្យនិសិត្សបញ្ញាវ័ន្តខ្មែរ បានឱ្យដឹងថា តាមពិតទៅប្រជាពលរដ្ឋ ជាង២០០គ្រួសារមកពីភូមិស្រែណូយឃុំស្រែណូយ មិនបានលក់ឱ្យក្រុមហ៊ុនទេ គឺឃុំជាអ្នកលក់ដីធ្លី៧០០ ហិកតានោះទៅឱ្យក្រុមហ៊ុន។ ក្រុមហ៊ុននេះបានឈូសឆាយដីកើតមានទំនាស់នោះតែប្រជាពលរដ្ឋបានតវ៉ាមិនឱ្យឈូសឆាយហើយក្រុមហ៊ុនបានឈូសឆាយបន្តទៀតនាពេលយប់ ។ ពីព្រោះតំណាងក្រុមហ៊ុនបាននិយាយថា គេបានផ្តល់លុយទិញដីពីប្រជាពលរដ្ឋដោយស្របច្បាប់ ប៉ុន្តែឃុំបានលួចលក់ហើយប្រជាពលរដ្ឋ ដែលជាសែស្រឡាយមេឃុំ ទទួលបានលុយ២០០ដុល្លារក្នុងមួយហិកតា ចំណែកប្រជាពលរដ្ឋភាគច្រើនមិនបានទទួលលុយទាំងនោះទេ ។ លោកបានបន្តទៀតថា ដីនោះអ្នកភូមិបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ ប៉ុន្តែក្រោយពីឆ្នាំ១៩៧៩ តំបន់ដែលប្រជាពលរដ្ឋរស់នោះ ពើបប្រទះនឹងការវាយប្រយុទ្ធគ្នាដូច្នេះប្រជាពលរដ្ឋពិបាកក្នុងការធ្វើស្រែចំការ តែក្រោយមកប្រទេសយើងមានសន្តិភាព ប្រជាពលរដ្ឋក៏នាំគ្នាដាំដុះដំណាំ និងធ្វើស្រែចិញ្ចឹមជីវិតដូចធម្មតាវិញ ។

លោក **ឆេម សារឿន** មេឃុំស្រែណូយ បានលើកឡើងថា អាជ្ញាធរឃុំ បានប្រកាសជូនដំណឹងដល់ប្រជាពលរដ្ឋហើយដែលទាក់ទងនឹងការធ្វើចំការនេចរ រដ្ឋាភិបាលនឹងសុំគោលការវិនិយោគជាមួយក្រុមហ៊ុនកូរ៉េ ដែលមានផ្ទៃដីចំនួន៧០០ហិកតា ។ ចំពោះចំការពនេចររដ្ឋដោះស្រាយគោលការឱ្យ២០០ដុល្លារ ក្នុងមួយហិកតា អាស្រ័យដោយចំការពនេចអ្នកភូមិមិនមែនជាកម្មសិទ្ធិរបស់អ្នកណាម្នាក់ទេ ។

## ប្រធានគណបក្សសិទ្ធិមនុស្សចុះសួរសុខទុក្ខ ប្រជាពលរដ្ឋនៅខេត្តកំពង់ឆ្នាំង

ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់ លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស បានចុះជួបសំណេះសំណាលបងប្អូនប្រជាពលរដ្ឋ នៅឃុំពេជ្រសង្វា ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ដោយប្រជាពលរដ្ឋ សកម្មជនគណបក្សសិទ្ធិមនុស្ស និងសកម្មជនគណបក្ស **សម រង្ស៊ី** ប្រមាណ២០០នាក់ចូលរួមផងដែរ ។

ថ្លែងទៅកាន់ប្រជាពលរដ្ឋនៅឃុំពេជ្រចង្វា លោក **កឹម សុខា** សមាជិករដ្ឋសភា មានប្រសាសន៍ថា គណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី បានបង្កើតសម្ព័ន្ធភាពតែមួយដោយដាក់ឈ្មោះថា **ចលនាប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរ** នេះមានគោលបំណងធំដើម្បីសេរីភាព សេដ្ឋកិច្ចល្អជាងហ្នឹង ។ គណបក្សដែលមាននិន្នាការប្រជាធិបតេយ្យសេរី បានផ្តុំគ្នាជាកំលាំងមហាសាមគ្គីតែមួយ ដែលនេះជាជំរើសងាយស្រួលសំរាប់ប្រជាពលរដ្ឋខ្មែរយើងធ្វើការផ្លាស់ប្តូរ ។

លោក **កឹម សុខា** ក៏បានសួរទៅកាន់ប្រជាពលរដ្ឋដែលកំពុងត្រង់ត្រាបស្តាប់ប្រសាសន៍លើកឡើង របស់ថ្នាក់ដឹកនាំរបស់គណបក្សសិទ្ធិមនុស្សផងដែរថា តើបងប្អូនចង់ឱ្យអត់ពេទ្យមើលទៀតឬយ៉ាងណា បើដូច្នេះមែនបងប្អូនបោះឆ្នោតឱ្យពួកកុំម្មុយនីស្តទៀតទៅ ។ ប៉ុន្តែបើបងប្អូនចង់ឱ្យមានជីវភាពល្អប្រសើរជាងសព្វថ្ងៃនេះ និងមានពេទ្យព្យាបាល អ្នកក្រីក្រអត់យកលុយដូចជាចាស់ជរាឱ្យមានប្រាក់ឧបត្ថម្ភ ជួយកូនអ្នកក្រីក្រឱ្យមានសាលារៀន មានការងារធ្វើ ដូច្នេះបងប្អូនគួរតែមកចូលផ្តុំជាមួយនយោបាយប្រជាធិបតេយ្យដើម្បីផ្លាក់ប្តូរ ។ លោកបានបន្តថាយើងបានចុះហត្ថលេខារួចហើយ ខាងគណបក្សសិទ្ធិមនុស្ស និង គណបក្សសម រង្ស៊ី ហើយយើងក៏បានសំរេចចិត្តហើយដែរថា នឹងមិនបែកបាក់គ្នា មានគោលជំហររឹងមាំដើម្បីការពារប្រយោជន៍ជាតិ និងប្រយោជន៍ប្រជាពលរដ្ឋ ។ លោកក៏បានសង្កត់ធ្ងន់ថា លោកមិនគិតអំពីតួនាទី និងតំណែងបុគ្គលនោះទេ ។

ប្រធានប្រតិបត្តិស្រុកបរិបូរណ៍របស់គណបក្សសិទ្ធិមនុស្ស បានប្រាប់ថា ការចូលរួមស្តាប់ប្រសាសន៍របស់ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស នៅក្នុងឃុំពេជ្រចង្វាមានតំណាង សកម្មជនគណបក្សសិទ្ធិមនុស្ស និងតំណាងសកម្មជនគណបក្ស សម រង្ស៊ី ព្រមទាំងប្រជាពលរដ្ឋមួយចំនួនលោកថា ចលនាប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរ ដែលលោក **កឹម សុខា** ជំរាបជូន ប្រជាពលរដ្ឋ គឺបង្ហាញនូវភាពរឹងមាំរបស់សម្ព័ន្ធនេះនាពេលអនាគត ពីព្រោះប្រជាពលរដ្ឋមានចិត្តក្លៀវក្លាក្នុងការរួបរួមសម្ព័ន្ធនេះ ។

## ចលនាប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរ នៅកម្ពុជា

នៅថ្ងៃព្រហស្បតិ៍ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ វេលាម៉ោង៩ព្រឹក នៅទីស្នាក់ការគណបក្ស សម រង្ស៊ី នឹងមានរៀបចំសន្និសីទសារពត៌មានទាក់ទង នឹងការចេញសេចក្តីថ្លែងការណ៍រួមគ្នាស្តីពីសម្ព័ន្ធភាពរវាងគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ថ្លែងប្រាប់សម្លេងសិទ្ធិមនុស្សកាលពីព្រឹកមិញនេះលោក **យ៉ែម បុញ្ញឫទ្ធិ** អគ្គលេខាធិការគណបក្សសិទ្ធិមនុស្ស បញ្ជាក់ថាការជួបប្រជុំរបស់ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស លោក **កឹម សុខា** និង ថ្នាក់ដឹកនាំគណបក្ស សម រង្ស៊ី មានលោក **សម រង្ស៊ី** និងក្រុមការងាររបស់គណបក្សទាំងពីរបានឯកភាពគ្នា នឹងរៀបចំសន្និសិទមួយនៅថ្ងៃព្រហស្បតិ៍នាទីស្នាក់ការគណបក្ស សម រង្ស៊ី ជុំវិញការចេញសេចក្តីថ្លែងការណ៍រួមមួយស្តីពីសម្ព័ន្ធភាព ។

លោក **យ៉ែម បុញ្ញឫទ្ធិ** បានបន្តទៀតថាយើងចង់ឱ្យមានកំលាំងរួមគ្នា និងជាជំរើសដល់ប្រជាពលរដ្ឋខ្មែរយើង និងក៏ជាកំលាំងមួយធំក្នុងការផ្លាស់ប្តូររបៀបដឹកនាំប្រទេស ។

ថ្លែងទៅកាន់អ្នកសារពត៌មានជាតិ និង អន្តរជាតិ លោក **សម រង្ស៊ី** បានថ្លែងថា សន្និសីទកាសែតរួមរវាងគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សនេះ ដើម្បីឱ្យមតិជាតិ និងអន្តរជាតិដឹងឱ្យច្បាស់អំពីគោលបំណងរួបរួមជាតិ តាមរយៈចលនាមហាប្រជាធិបតេយ្យមួយដែលគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានសំរេចបង្កើត និងអំពាវនាវឱ្យកំលាំងស្នេហាជាតិ និង កំលាំងប្រជាធិបតេយ្យដទៃទៀត ។ ជាពិសេសអ្នកដែល

ស្រលាញ់យុត្តិធម៌ឱ្យចូលរួម ក្នុងមហាចលនាប្រជាធិបតេយ្យនេះ ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរនៅប្រទេសកម្ពុជា ។

លោក **សម រង្ស៊ី** បានបន្តទៀតថា ចលនាមហាប្រជាធិបតេយ្យនេះគឺជា សេចក្តីសង្ឃឹមជាជំរើសថ្មីមួយសំរាប់ប្រជារាស្ត្រខ្មែរ ដែលចង់ឱ្យមានការផ្លាស់ប្តូរនៅប្រទេសកម្ពុជា ដើម្បីឱ្យមានការផ្លាស់ប្តូរនេះ ។ លោកថ្លែងសង្កត់ធ្ងន់ថាដើម្បីឱ្យមានការផ្លាស់ប្តូរនេះទាល់តែកំលាំងអ្នកស្នេហាជាតិប្រជាធិបតេយ្យ កំលាំងអ្នកស្រលាញ់យុត្តិធម៌រួបរួមគ្នាដើម្បី មានកំលាំងគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូររបៀបដឹកនាំប្រទេស នាពេលអនាគតដ៏ខ្លីខាងមុខនេះ ។

លោក **សម រង្ស៊ី** បានបន្តថា ប្រទេសប្រជាធិបតេយ្យពិតប្រាកដ គេតែងតែមានការផ្លាស់ប្តូរដើម្បីទទួលបាននូវការរីកចំរើនពិតប្រាកដ លោក **សម រង្ស៊ី** ក៏បានចាត់ទុកថា នេះជាពេលវេលាល្មមដល់ហើយក្នុងការរៀបចំចលនាប្រជាធិបតេយ្យឱ្យលេចចេញជារូបរាង ដើម្បីឱ្យកំលាំងប្រជាធិបតេយ្យពិតប្រាកដមានបញ្ជីបេក្ខជនតែមួយនៅក្នុងការបោះឆ្នោត ខាងមុខនេះដោយមិនចាំបាច់ការបោះឆ្នោតថ្នាក់ជាតិឆ្នាំ ២០១៣ខាងមុខនេះ គឺចាប់ពីការបោះឆ្នោតឃុំ-សង្កាត់ ២០១២ ខាងមុខនេះតទៅ ។

ថ្លែងទៅកាន់ក្រុមអ្នកសារពត៌មាន លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្សបានកំណត់ថា ថ្ងៃនេះគឺជាប្រវត្តិសាស្ត្រសំរាប់ប្រជាពលរដ្ឋខ្មែរយើងពីព្រោះ គណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី បានធ្វើចលនាប្រជាធិបតេយ្យជាយូរយារមកហើយនោះ ឥឡូវនេះដល់ហើយដែលយើងសំរេចចិត្តប្រមូលផ្តុំកំលាំងអ្នកប្រជាធិបតេយ្យ និងជាតិនិយមពិតប្រាកដដើម្បីឈានទៅរកការផ្លាស់ប្តូរនៅក្នុងសង្គមជាតិរបស់យើង ដើម្បីឱ្យប្រទេសជាតិមានសេដ្ឋកិច្ចលូតលាស់សំរាប់ប្រជាពលរដ្ឋ និងមានសង្គមមួយជាសង្គមប្រជាធិបតេយ្យ ។ ម្យ៉ាងទៀតការប្រមូលផ្តុំកំលាំងប្រជាធិបតេយ្យពិតប្រាកដដ៏រឹងមាំនោះ ដើម្បីផ្តល់ជំរើសងាយស្រួលដល់ប្រជាពលរដ្ឋខ្មែរ ក្នុងការធ្វើសេចក្តីសំរេចចិត្តជ្រើសរើសនូវរបៀបដឹកនាំប្រទេស ។

សម្ព័ន្ធភាពនេះក៏ឆ្លើយតប នឹងការលើកទឹកចិត្តដល់ប្រជាពលរដ្ឋខ្មែរដែលបងប្អូនទន្ទឹងរងចាំ និងទទូចចង់បានយូរណាស់ហើយ ដោយចង់ឃើញកំលាំងប្រជាធិបតេយ្យពិតប្រាកដ ដែលមានកំលាំងរឹងមាំគោលជំហរច្បាស់លាស់រួបរួមគ្នា ដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋក្នុងការសំរេចចិត្តពេលបោះឆ្នោតខាងមុខនេះ ។ លោក **កឹម សុខា** បានមានប្រសាសន៏ទៀតថា គោលជំហររបស់គណបក្សសិទ្ធិមនុស្ស និងគណបក្សសម រង្ស៊ី មិនដែលទន់ជ្រាយនោះទេ ហើយយើងធ្វើនយោបាយក៏មិនមែនដើម្បីរណបគណបក្សណាមួយ ឬបរទេសណានោះដែរពោលគឺយើងធ្វើដើម្បីយកឆន្ទះប្រជាពលរដ្ឋជាធំ ត្រង់ចំណុចនេះហើយដែលយើងជាចលនាប្រជាធិបតេយ្យរឹងមាំ ។

សូមជំរាបថា ក្រៅពីការវិលត្រឡប់របស់លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស មកពីសហរដ្ឋអាមេរិក កាលពីខែធ្នូ ឆ្នាំ២០០៨ ឃើញថាប្រជាពលរដ្ឋខ្មែររស់នៅទាំងក្នុង និងក្រៅប្រទេសបានសំណូមពរ និងទទូចដល់លោក **កឹម សុខា** ស្នើឱ្យ គណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី រួបរួមគ្នាជាសម្ព័ន្ធភាពតែមួយ ហើយក៏ជានិច្ចជាកាល ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សតែងតែស្នើឱ្យមានការបង្កើតជាសម្ព័ន្ធភាពតែមួយ ។

| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| **លោក** | **ម៉ី សាន** | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| **កញ្ញា** | **គង់ ចន្ណា** | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |

**ចលនាប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរនៅប្រទេសកម្ពុជា !**